អេម៉ាន់អែល

សំលេងពីព្រះសហគមន៍កាតូលិក

FM: 91 Mhz ខេត្តបាត់ដំបង

៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 88 Mhz ខេត្តកំពង់ធំ

១៦:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 102.5 Mhz ខេត្តសៀមរាប

១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍ កាតូលិក រតនៈ

- *បំលែងឯកសារពី VHS ទៅ DVD ទៅ VCD*
- *បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD*
- *បង្កើតឯកសារឌីជីអូ សំរាប់ លោកនីពុក បងស្រី បងប្រុសៗ*

ទំនាក់ទំនង ០៩២ ៦០៩ ៨៦៨

ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

•ថ្ងៃទី០១-១០ មករា : មានក្រុមយុវជន ដែលមកពីប្រទេសកូរ៉ែ បានមកបំពេញបេសកកម្ម នៅព្រះសហគមន៍ កំពង់គោ ដែលមានរយៈពេលស្នាក់នៅចំនួនដប់ថ្ងៃ។ ក្នុងនោះ យុវជនកូរ៉ែ ដែលអញ្ជើញមកនេះមានចំនួន ២០នាក់ ដែលចែកចេញជាពីរក្រុម។ គោលបំណងរបស់ក្រុមយុវជនកូរ៉ែមកបំពេញបេសកកម្មនេះ គឺជាការរឹតចំណងមិត្តភាពរវាងយុវជនកូរ៉ែ និងយុវជនព្រះសហគមន៍កំពង់គោ ព្រមទាំងការចែករំលែកនូវបទពិសោធន៍ទៀតផង។ រយៈពេលនៃការស្នាក់នៅរបស់ពួកគេ ពួកគេបាននាំគ្នាជួយជួសជុលរបងព្រះវិហារ និងការដាំដើមឈើ ព្រមទាំងការសំអាតទីធ្លា ឬនៅជុំវិញបរិវេន ព្រះវិហារ។

ល្បែងកំសាន្ត

ផ្លូវមានបី តើកណ្តុលត្រូវជ្រើសរើសយកផ្លូវមួយដើម្បីយកនំនោះបាន?



Apostolic Prefecture of Battambang Monthly News. For Internal Circulation

រតនៈ
RATTANAK

មហាគ្រួសារព្រះសហគមន៍
កាតូលិក
Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ មករា ឆ្នាំ ២០១៣ លេខ ៤៦

កម្មវិធីបើកវគ្គបណ្តុះបណ្តាល អ្នកណែនាំអប់រំជំនឿ

មាតិកា

- ខួបទី ៥0ឆ្នាំនៃមហាសន្និបាតវ៉ាទីកង់ទី២ ទំព័រ ២
- កម្មវិធីបើកវគ្គមណ្ឌលបណ្តុះបណ្តាល សាលិស៊ាន ទំព័រ ៦
- ទស្សន:កិច្ចរបស់បងប្អូនគ្រីស្តបរិស័ទ អង់គ្លីកាំងកើត ទំព័រ ៤-៥

ខួបទី ៥០ឆ្នាំនៃមហាសន្និបាត វ៉ាទីកង់ទី២

Photo: An Rittyrath

ដោយ:អាន ឬទ្ធីរដ្ឋ និង ស៊ីអេសស៊ី

កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ ២០១២ នៅដីថ្មីរបស់ព្រះសហគមន៍ កាតូលិកភូមិភាគភ្នំពេញ នៅខណ្ឌ សែនសុខ រាជធានីភ្នំពេញ បានប្រារព្ធពិធីសន្និសីទរំព្ងកខួប ៥០ ឆ្នាំនៃមហាសន្និបាតវ៉ាទីកង់ទី២ យ៉ាងឱឡារឹក។ មហាសន្និបាតនេះ ធ្វើឡើងក្នុងគោលបំណង ចង់ឲ្យគ្រីស្តបរិស័ទទាំងអស់យល់ថា ព្រះគ្រីស្ត គឺជាពន្លឺប្រជាជាតិនានា ហើយយើងចង់ផ្សព្វផ្សាយពន្លឺនេះ ទៅមនុស្សទាំងអស់។ ម៉ាងវិញទៀត ចង់ឲ្យគ្រីស្តបរិស័ទទាំងអស់ យល់ថាព្រះសហគមន៍ កាតូលិក គឺជាផ្នែកមួយ ដែលជួយឲ្យយើងមើលឃើញពីគុណធម៌មួយ នៅក្នុងសង្គម។ ក្នុងនោះមានការចូលរួមក្រោមអធិបតីភាព របស់លោកអភិបាលទាំងបីភូមិភាគ ព្រមទាំងបងប្អូនគ្រីស្តបរិស័ទចំនួនប្រមាណ ៥០០នាក់ ដែលបានមកពីព្រះសហគមន៍ ទាំងបីភូមិភាគផងដែរ។ លោកអភិបាលអូលីវិយេជ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍ កាតូលិកភ្នំពេញ បានមានប្រសាសន៍ថា "នេះគឺជាមហាសន្និបាត ដែលមានគ្រីស្តបរិស័ទ លោកបូជាចារ្យ បងប្រុសបងស្រី មកពីគ្រប់ទិសទីទូទាំងប្រទេស ជួបជុំគ្នា ពិភាក្សាដើម្បីអភិវឌ្ឍព្រះសហគមន៍ និងប្រទេសកម្ពុជា ហើយសម្តេច ប៉ាបបេណាទីតូទី១៦ ក៏បានផ្ញើសារជា វីដេអូដល់មហាសន្និបាតនេះផងដែរ។ ចំណែកលោកអភិបាល គីគេ ហ្វីការេដូ ជាអភិបាលទទួលខុសត្រូវនៅក្នុងភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា "នេះជាមហាសន្និបាត គ្រីស្តបរិស័ទមួយ ដែលបង្ហាញថា ព្រះសហគមន៍ កាតូលិកនៅកម្ពុជា កំពុងតែរួមរស់ជាមួយគ្នា នៅក្នុងនាមជាប្រជារាស្ត្រ របស់ព្រះជាម្ចាស់"។ នៅក្នុងអំឡុងជួបជុំគ្នារយៈពេលបីថ្ងៃនេះ គ្រីស្តបរិស័ទទាំង ដែលបានចូលរួមនៅក្នុងមហាសន្និបាត បានចែកគ្នាជា ៨ក្រុម ដោយពិភាក្សាគ្នាលើប្រធានបទ ៨ ដែលរួមមានដូចជា ព្រះសហគមន៍ និងទំនាក់ទំនងជាមួយ នឹងសាសនាដទៃ ព្រះសហគមន៍ និងការអធិដ្ឋាន ព្រះសហគមន៍ និងការប្រកាសដំណឹងល្អ ព្រះសហគមន៍ និងការត្រាស់ហៅ ព្រះសហគមន៍ និងការផ្សព្វផ្សាយ ព្រះសហគមន៍ គ្មានធនធាន តែបម្រើអ្នកក្រ ព្រះសហគមន៍ និងការអប់រំ ចំណែកងប្រធានបទចុងក្រោយគឺ ព្រះសហគមន៍ និងសង្គមបច្ចុប្បន្នកាល។ កម្មវិធីមហាសន្និបាត វ៉ាទីកង់ទី២ នេះបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ ដោយមានឆ្លើយតបទៅនឹងការចូលរួមអភិវឌ្ឍន៍ព្រះសហគមន៍ និងបង្ហាញអំពីគោលដៅ ពង្រឹងជំនឿ ស្របតាមការប្រកាស របស់ព្រះសហគមន៍ថា ជាឆ្នាំនៃជំនឿ។

សន្តី ថេរេសា នៅក្រុង លីស៊ីយឺ

ក្នុងរតនៈលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ីយឺ រីឯលេខនេះគឺ យើងបន្តអាន នូវប្រវត្តិ របស់សន្តី ថេរេសា បន្តទៀត។ តើ ថេរេសា មានសេចក្តីប៉ង ប្រាថ្នាយ៉ាងណាខ្លះចំពោះព្រះជាម្ចាស់? តើ ថេរេសា មានចិត្តយ៉ាងណានៅពេល ដែលគេបានយកផ្កាមកអោយរូបនាង?

ថ្ងៃមួយ វេលាម៉ោងពីរព្រឹក ថេរេសា បានក្អូតឈាម និងនិយាយថា៖ "នាងខ្ញុំដឹងថាបន្តិចទៀត នាងខ្ញុំនឹងចូលសំរាក។ នៅពេលហ្នឹង បេសកកម្មរបស់នាងខ្ញុំ ទើបចាប់ផ្តើមគឺនាងខ្ញុំចង់ឲ្យមនុស្សឯទៀតៗ ស្រឡាញ់ព្រះជាម្ចាស់ ដូចនាងខ្ញុំ បានស្រឡាញ់ព្រះអង្គ ហើយនាងខ្ញុំ សូមប្រគល់ផ្លូវដ៏តូចតាចសាមញ្ញឲ្យមនុស្សឯទៀតៗ ដើរតាមដែរ។ ពេលនាងខ្ញុំនៅស្ថានបរមសុខ រួមជាមួយព្រះអង្គ នាងខ្ញុំនៅតែជួយ បងប្អូន ដែលរស់នៅក្នុងលោកនេះ តទៅទៀត"។ នៅថ្ងៃទី ១១សីហា៖ "នាងខ្ញុំអត់ស្មានថា នាងខ្ញុំត្រូវឈឺ បែបនេះទេ! នាងខ្ញុំឈឺចាប់ដូចកូនតូច នាងខ្ញុំមិនចង់សូមឲ្យព្រះជាម្ចាស់ ប្រទានសេចក្តីឈឺចាប់ខ្លាំងជាងនេះទៀតក៏ប៉ុន្តែប្រសិនប្រទានឲ្យនាងខ្ញុំ ក៏សុខចិត្តទទួលអ្វីៗ ដែលមកពីព្រះជាម្ចាស់ ដោយរីករាយ។ នាងខ្ញុំផ្ទាល់ ជាជនតូចតាចគ្មានកម្លាំងសោះ"។ "នាងខ្ញុំស្រឡាញ់ព្រះអម្ចាស់ណាស់ចាំ ស្រឡាញ់ណាស់"។ ១៤កញ្ញា គេយកផ្កាកុលាបមួយមកឲ្យនាង។ នាងពាក់ត្របកផ្កាទៅលើឈើឆ្កាងដែលនាងកាន់ដោយពោលថា៖ "នាងខ្ញុំចង់ស្រក់ទឹកភ្នែក និងឈាមរបស់ព្រះអង្គ"។ពេលត្របកផ្កាក្រោម នាងប្រាប់ថា៖ "បងស្រី! ចូរប្រមូលត្របកផ្កានេះ ពេលក្រោយបងស្រីអាចប្រើវាដើម្បីធ្វើឲ្យមនុស្ស ជាច្រើនសប្បាយចិត្ត"។ "អ្ងំ!ប្អូនឯងឈឺខ្លាំងមែនទែនគួរឲ្យអាណិត!"។ "នាងខ្ញុំ បានទទួលជំនឿ ជាព្រះអំណោយទាន។ បើនាងខ្ញុំគ្មានជំនឿទេ នាងខ្ញុំ ពិតជាសម្លាប់ខ្លួនឯងជាមិនខាន"។ ៣០កញ្ញា ពេលព្រឹក ថេរេសា មិននិយាយអ្វីសោះ។ នាងដកដង្ហើមមិនរួចហើយហត់ ,នាងឈឺមែនទែនជិតដាច់ខ្យល់ គ្មានសេចក្តីរីករាយសោះ។.....(តលេខក្រោយ)

កម្មវិធីបើកវគ្គសិស្សថ្មី របស់មណ្ឌលបណ្តុះបណ្តាល សាលិសាន

ដោយៈ អាន ឬទ្ធិរដ្ឋ

Photo: Rath

កាលពីថ្ងៃទី២៦ ខែមករា កន្លងទៅថ្មីៗនេះនៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សាលិសាន បានប្រារព្ធពិធីបើកវគ្គ សម្រាប់ទទួលសិស្សថ្មី ដើម្បីរៀនយកជំនាញក្នុងឆ្នាំសិស្ស ២០១២,២០១៣។ ក្នុងមណ្ឌលនោះ មានបងស្រី លក្ខិណា ជាអ្នកគ្រប់គ្រងមណ្ឌល។ កម្មវិធីបើកវគ្គថ្មីនេះ មានអ្នកចូលរួមប្រមាណជាង ១០០នាក់ ក្នុងនោះមានមាតាបិតាសិស្ស សិស្សចាស់ ម្តាយ សិស្សថ្មី លោកគ្រូ អ្នកគ្រូ ព្រមទាំងបងស្រីផងដែរ។ ខណៈពេលកម្មវិធីបើកវគ្គនេះ មណ្ឌលបានបញ្ចូលនូវការបង្ហាញអំពីតួនាទី របស់មាតាបិតាក្នុងការចិញ្ចឹមបីបាច់ ថែរក្សាអស់កូនៗ។ ក្នុងកម្មវិធីនោះចង់បង្ហាញអោយមាតាបិតា ទាំងអស់ និងអ្នកដែលត្រៀមខ្លួន ធ្វើជាឪពុក ម្តាយ ផ្សេងៗរបស់ខ្លួន និងហាន:ជាឪពុក ម្តាយ។ ដូចនេះសំរាប់កម្មវិធីបើកវគ្គសិស្សថ្មីនេះ គឺមានគោលបំណងបង្ហាញអំពីតួនាទី របស់មាតាបិតា ក្នុងការបីបាច់ថែរក្សាកូនចៅ។ ខណៈពេលនោះបងស្រី លក្ខិណា បានមានប្រសាសន៍ថា"ខ្ញុំសង្ឃឹមថា ធ្វើជាឪពុក សិក្ខាសាលាបង្ហាញថ្ងៃនោះ ធ្វើឲ្យមាតាបិតាល្អក្នុងសង្គម"។ ពេលបញ្ចប់នៃកម្មវិធី បងស្រីបានអោយមាតាបិតាសិស្សទាំងអស់ ចូលទៅក្នុងថ្នាក់រៀន ដើម្បីពិនិត្យមើលនូវពិន្ទុរបស់កូនៗ ដែលបានសិក្សាកន្លងមក។ នៅពេលនោះកូនសិស្សទាំងអស់ ក៏បានបង្ហាញអារម្មណ៍យ៉ាងសប្បាយចិត្តថា ពួកគេមកទីនេះទទួលនូវចំនេះដឹងច្រើន ពីសាលា និងទទួលរប្រៀបក្នុងការរស់នៅជាក្រុមដោយមានការសាមគ្គីគ្នាក្នុងការរស់នៅក្នុងមណ្ឌល ទៀតផង។ ពេលនោះក៏មានការថតរូបជាមួយគ្នា ទុកជាអនុស្សាវរីយ៍ និងមានការទទួលនូវអារម្មណ៍ សំរ៉ែន់ពីកម្មវិធីបើកវគ្គនោះផងដែរ។

កម្មវិធីបើកវគ្គបណ្តុះបណ្តាល អ្នកណែនាំអប់រំជំនឿ



Photo: Moy Samet

ដោយៈ មុយ សាម៉ែត

នៅព្រះសហគមន៍ កាតូលិក អញ្ជើញមកពីបីតំបន់ ដូចជាតំបន់បាត់ដំបង កាលពីល្ងាចថ្ងៃទី២៥ មករា ឆ្នាំ២០១៣ មានពិធីអភិបូជាជាមួយ និងកម្មវិធីបើកវគ្គបណ្តុះបណ្តាល អ្នកណែនាំអប់រំជំនឿ និងពិធីសច្ចា។ កម្មវិធីនេះធ្វើឡើងក្នុងគោលបំណង ដើម្បីឲ្យលោកគ្រូ អ្នកគ្រូ ដែលជាអ្នកណែនាំនៃជំនឿ ធ្វើសច្ចាចំពោះមុខព្រះជាម្ចាស់ និងទទួលការប្រសិទ្ធិពរ ពីសំណាក់លោកអភិបាល។ កម្មវិធីនេះ ក៏មានការចូលរួមពីលោកអភិបាល គឺគេហ្វីការេដូ ដែលជាអ្នកទទួលខុសត្រូវនៅក្នុងភូមិភាគ បាត់ដំបង លោកបូជាចារ្យ ម៉ានុច លោកបូជាចារ្យសុផល ព្រមទាំងគណៈកម្មាការណ៍លោកគ្រូ អ្នកគ្រូ ដែលខុសត្រូវនៅក្នុងភូមិភាគ បាត់ដំបង ឲ្យស្មគ្រគិតគាំទ្រ កម្មវិធីបណ្តុះបណ្តាលអ្នកណែនាំជំនឿ នៅក្នុងឆ្នាំនៃជំនឿ"។ លោកអភិបាល គីគេ បានមានប្រសាសន៍ផ្តាំផ្ញើរទៅដល់លោកគ្រូ អ្នកគ្រូ ដែលជាអ្នកណែនាំ និងអប់រំជំនឿផងដែរថា "សម្រាប់លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមចង់ចាំនូវបីចំណុច ដូចជា ប្រាជ្ញា ចិត្ត និងសកម្មភាព"។ ជាពិសេសទៅទៀត នោះលោកអភិបាល បានសង្កត់ធ្ងន់ទៅលើសេចក្តីស្រឡាញ់ ចំពោះលោកគ្រូ អ្នកគ្រូ ដែលត្រូវមានភារៈកិច្ចបង្រៀន និងណែនាំងអប់រំជំនឿផងដែរ។ បន្ទាប់ពី ពិធីអភិបូជា និងពិធីសច្ចា ជាមួយការប្រទានពរ របស់លោកអភិបាលរួមមក លោកគ្រូ សុខ ហោង មានអាយុ២៥ឆ្នាំ ដែលមកពី ព្រះសហគមន៍ សៀមរាប បានមានប្រសាសន៍ផងដែរថា "នៅក្នុងថ្ងៃនេះ ខ្ញុំមានអារម្មណ៍ថា សប្បាយចិត្តខ្លាំងណាស់ ពីព្រោះឥលូវនេះនៅក្នុងភូមិភាគបាត់ដំបង របស់យើងបានបើកវគ្គបណ្តុះបណ្តាលនេះ។ កម្មវិធីនេះពិតជាមាន សារៈសំខាន់ណាស់ចំពោះជំនឿយើងទាំងអស់គ្នា។

Photo: An Rittyrath

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ នៅក្នុងមណ្ឌលប៉ាស្ទ័រាល អូស្ការ រ៉ូម៉ឺរ៉ូ ដែលស្ថិតនៅក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង មានការប្រជុំលើយុទ្ធសាស្ត្របីឆ្នាំចុងក្រោយ។ ការប្រជុំនេះគឺផ្តោតសំខាន់ ទៅលើយុវជននៅពេលបច្ចុប្បន្ន និងយុវជនទៅអនាគត។

Photo: Tom Cheat

ពិធីអបអរសាទរបុណ្យខួប ២២៣ឆ្នាំ នៃព្រះសហគមន៍ កាតូលិក ភូមិភាគបាត់ដំបង បានប្រារព្ធឡើងកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៣។ ពិធីបុណ្យនេះចាប់ផ្តើមប្រព្រឹត្តទៅនៅវេលាម៉ោង ០៥ :៣០នាទីល្ងាច នៅខាងមុខផ្ទះលោកអភិបាលគីគេ ហ្វីកាវេដូ ដោយមានក្បួនដង្ហែរូបសំណាក់ព្រះនាងម៉ារី ទៅក្នុងព្រះវិហារធំ ដើម្បីថ្វាយអភិបូជា។ នៅពេលរាត្រី ក៏មានកម្មវិធីកម្សាន្ត និងសំនូរចម្លើយ។

ទស្សនៈកិច្ចរបស់បងប្អូនគ្រីស្តបរិស័ទ អង់គ្លៀខាងកើត

Photo: Mov Samet

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ ២០១៣ ស្របពេលអភិបូជានៅក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង បានទទួលភ្ញៀវ ដែលអញ្ជើញមកពីអង់គ្លៀខាងកើត នៃប្រទេសអង់គ្លេស។ គោលបំណងដែលពួកគាត់អញ្ជើញមកទីនេះ គឺដើម្បីចុះសួរសុខទុក្ខ និងការបង្កើតចំណងមិត្តភាព រវាងប្រជាជាតិទាំងពីរ។ រយៈពេលនៃការស្នាក់នៅរបស់ក្រុមអង់គ្លៀខាងកើត ដោយមានការដឹកនាំពីលោកឪពុក ម៉ាក បានចុះទៅទស្សនៈកិច្ចតាមព្រះសហគមន៍មួយចំនួនដូចជា ព្រះសហគមន៍កំពង់ឆ្នាំង សៀមរាប ប៉ៃលិន ច្រាបវាល ចំណោម ឈើទាល និងព្រះ-សហគមន៍ កាតូលិកបាតដំបង។ លោកឪពុកតូតេតក៏បានមានប្រសាសន៍ផងដែរថា នៅក្នុងថ្ងៃនេះមានភ្ញៀវរបស់យើង ដែលមកពីប្រទេសអង់គ្លេស គឺមកពីព្រះសហគមន៍ណារ វីល សិន នៅអង់គ្លៀខាងកើត ជាមួយនិងអ្នកជំនួយការ និងអ្នកទទួលខុសត្រូវនៅក្នុងភូមិភាគ គឺលោកឪពុក ម៉ាក។ ហើយពួកគាត់មកទីព្រះសហគមន៍ របស់យើងជារៀងរាល់ឆ្នាំ ហើយនេះគឺជាទំនាក់ទំនងដ៏ល្អរវាងព្រះសហគមន៍ របស់យើងទាំងពីរ និងរវាងបងប្អូនគ្រីស្តបរិស័ទផងដែរ។ ដោយ:មុយ សាម៉ែត

Photo: An Rittyrath

កាលពីថ្ងៃទី ២៧ ខែ មករា កន្លងទៅនេះ នៅព្រះសហគមន៍កាតូលិកបាត់ដំបងបានប្រារព្ធកម្មវិធីអបអរសាទរពិធីបិទឆ្នាំព្រះមហាករុណាទិគុណ គំរប់ខួប២៥០ឆ្នាំនៃក្រុមគ្រួសារបងស្រីឧបការគុណ(ក្រុមបងស្រី ប្រ៊ូវដង់) នៅព្រះសហគមន៍ កាតូលិកបាត់ដំបង។ ដោយមានការចូលរួមពីក្រុមគ្រួសារបងស្រីចំនួន ១៩នាក់ ព្រមទាំងគ្រីស្តបរិស័ទយ៉ាងច្រើនផងដែរ។

បងប្រុស សូ យើង បានបញ្ចប់បេសកកម្ម នៅព្រះសហគមន៍ កាលិកបាត់ដំបង



Photo: Moy Samet

បងប្រុស សូ យើង បានបញ្ចប់បេសកកម្ម នៅព្រះសហគមន៍ កាតូលិកបាត់ដំបង កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣។ បងប្រុសបានស្នាក់នៅ និងបំពេញកិច្ចការនៅព្រះសហគមន៍ បាត់ដំបង អស់រយៈពេល២ឆ្នាំ ហើយនៅក្នុងនោះ បងប្រុសបានបំពេញកិច្ចការ ជាច្រើនដូចជា សកម្មភាពរបស់ក្រុមយុវជន (SSVP) វិស័យកីឡា និងតន្ត្រី។ បងប្រុសបានបង្កើតកម្មវិធីមួយ ហើយជាក៏ជាកម្មវិធីលើកដំបូងផងដែរ សម្រាប់ព្រះសហគមន៍ បាត់ដំបង គឺកម្មវិធីថ្នាក់បង្រៀនដូរតន្ត្រីពេទ្យយាយជី ដែលមានឈ្មោះហៅកាត់ថា (PMP)។ ទស្សនៈរបស់បងប្រុសចង់បង្កើតកម្មវិធីនេះឡើង គឺក្នុងគោលបំណង ចង់អោយយុវជន ជៀសឆ្ងាយពីអំពើអាក្រក់ទាំងឡាយ ដែលកើតមាននៅក្នុងសង្គម អោយចាប់យកការលេងតន្ត្រីនេះវិញ។ មិនត្រឹមតែកម្មវិធីមួយនេះទេ រាល់គ្រប់កម្មវិធីទាំងអស់ បងប្រុសក៏មានទស្សនៈបែបនេះផងដែរ។ បងប្រុស ក៏បានបង្កើតកម្មវិធីបាល់ទាត់មិត្តភាពយុវជន និងកូនក្មេង ហើយបងប្រុស ក៏មានការគាំទ្រលើកីឡាតេក្វាន់ដូ ផងដែរ។ ទំនាក់ទំនងរវាងបងប្រុស ជាមួយយុវជនគ្រប់មជ្ឈដ្ឋាន គឺមានទំនាក់ទំនងយ៉ាងស្និតរមួត។ **ដោយ:មុយ សាម៉ែត**